ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង ៖ ០៤០/២០ - ខ្មែរ អេឡិកទ្រីខល ផៅវ័រ**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **សេង វួចហ៊ិន**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណាន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ័រ**

អាសយដ្ឋាន ៖ ផ្លូវលេខ២១៧ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៩២ ៦២៦ ៥៥៥ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការ៖

| | |
|---|---|
| ១- លោក មូល សុមីណា | គណនេយ្យ និងរដ្ឋបាល |
| ២- លោក សេង ចន្ថា | គណនេយ្យ និងរដ្ឋបាល |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ័រ**

អាសយដ្ឋាន ៖ ផ្លូវលេខ២១៧ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២៤៣ ៤៤ ១៦ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

| | |
|---|---|
| ១- លោក ដួង វាសនា | មន្ត្រីច្បាប់សហភាពការងារកម្ពុជា |
| ២- លោក សំ ចំរើន | មន្ត្រីច្បាប់សហភាពការងារកម្ពុជា |
| ៣- លោក កាន សុគារ | មន្ត្រីចងក្រង & ដោះស្រាយវិវាទCLC |
| ៤- លោក ហួន សំបូរ | ប្រធានសហជីពមូលដ្ឋាន |
| ៥- លោក ណុប ចាន់ដារ៉ា | លេខាសហជីព |

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

៦- លោក សៀង សុបិន          សមាជិកសហជីព

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

- កម្មករនិយោជិតនៅតែទាមទារ ឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួល ១៣០% ជូនកម្មករនិយោជិតដែល ធ្វើការប្តូរវេនជាក់ស្តែង ចាប់ពីម៉ោង ២២យប់ ដល់ម៉ោង ៥ភ្លឺ ដែលមានចែងក្នុងមាត្រា ១៤៤ថ្មី និងមាត្រា ១៣៩ នៃច្បាប់ស្តីពីការងារ។ ដោយឡែក តំណាងក្រុមហ៊ុនបានបញ្ជាក់ថា ក្រុមហ៊ុនចង់បានលិខិត ឬឯកសារ ណាមួយ ដែលច្បាស់លាស់ ដើម្បីបញ្ជាក់ថា ការទាមទាររបស់កម្មករនិយោជិត គឺត្រឹមត្រូវតាមច្បាប់ស្តីពីការងារ ដើម្បីក្រុម-ហ៊ុនសម្រេចបានតាមការទាមទារ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨៥/២០ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ (អាណត្តិទី១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខ្មែរ អេឡិកទ្រិខល ផៅវ័ លេខ ៦២៩ ក.ប/អក/វក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញា-កណ្តាល នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ** ៖ ថ្ងៃពុធ ៣រោច ខែអាសាឍ ឆ្នាំជូត ឯកស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។

**បញ្ហានីតិវិធី៖**

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

ក- ឯកសារបានទទួលពីភាគីនិយោជក

១- លិខិតផ្ទេរសិទ្ធិរបស់លោក Wichean Choriadda ជានាយកក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ័ រ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំផ្ទេរសិទ្ធិជូន លោក មូល សុមីណា ។

២- កំណត់ហេតុស្តីពីការសាកសួរព័ត៌មានពីតំណាងនិយោជកនៃក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ័រ ចុះថ្ងៃសុក្រ ១៤រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៩ ខែមិថុនា ឆ្នាំ ២០២០។

៣- ប័ណ្ណពន្ធប៉ាតង់ក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ័រ លេខ PTM-២០២០០៣៦៥៤៨ អពដ ចុះថ្ងៃ ទី១៦ ខែមីនា ឆ្នាំ២០២០។

៤- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ័រ លេខ MOC-៨០២២៣០៩១ ពណ.ចបព ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៤។

៥- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ័រ បានចុះបញ្ជីកាលេខ ១២៤៦ មកបវ ចុះថ្ងៃ ទី ១២ ខែមីនា ឆ្នាំ២០១៥ ដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានីភ្នំពេញ។

៦- លក្ខន្តិកៈក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ័រ បានតម្កល់ទុកលេខ ១៨៩/០៤ ព.ណ.នតក.បព ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៤ នៅការិយាល័យចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតចុះថ្ងៃអង្គារ ២រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី៧ ខែកក្កដា ឆ្នាំ ២០២០ របស់កម្មករនិយោជិត និងជាសហជីពនៃក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ័រ គោរពជូន លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីជូនសារណានៃក្រុមហ៊ុនខ្មែរអេឡិកទ្រីខលផៅវ័រ។

២- ពាក្យសុំជួយដោះស្រាយ និងលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃចន្ទ ៣រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២០ របស់កម្មករនិយោជិតនៃក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ័រ គោរពជូន លោកប្រធានសហភាពការងារកម្ពុជា (CLC) ស្តីពីស្នើសុំ លោកប្រធានជួយ ចូលរួមធ្វើជាតំណាងអម និងសម្រេចជាមួយយើងខ្ញុំ ក្នុងការដោះស្រាយវិវាទការងាររួម រវាងកម្មករ និយោជិត និងនិយោជក នៃក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ័រ។

៣- លិខិតស្នើសុំ និងចាត់តាំងប្រតិភូចរចា ចុះថ្ងៃចន្ទ ៣រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២០ របស់កម្មករនិយោជិតនៃក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ័រ គោរពជូន លោកប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីស្នើសុំជួយផ្សះផ្សាវិវាទការងារ រវាងយើងខ្ញុំ ជាមួយក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ័រ។

៤- កំណត់ហេតុស្តីពីកិច្ចពិភាក្សាអំពីលក្ខខណ្ឌការងារ និងសិទ្ធិព្រមទាំងអត្ថប្រយោជន៍ ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០។

៥- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ័រ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០។

៦- ឯកសារជាភាសាបរទេស។

THE ARBITRATION COUNCIL

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ័រ លេខ ៦២៩ ក.ប/អក/វក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ័រ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ័រ លេខ ០២៤ កប/អក/វក/កវក៤ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០ របស់នាយកដ្ឋានវិវាទការងារ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតលេខ ២៣៥ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ៥កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ របស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ជម្រាបមក លោកនាយកក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ័រ ស្តីពីការជ្រើសរើសអាជ្ញាកណ្តាល។

២- កំណត់ហេតុស្តីពីការចាប់ឆ្នោតជ្រើសរើសអាជ្ញាកណ្តាលពីបញ្ជីឈ្មោះអាជ្ញាកណ្តាល ស្នើដោយសមាគមនិយោជក ចុះថ្ងៃចន្ទ ៩កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹង ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ២៤២ កប/អក/វក/លកអ. ចុះថ្ងៃអង្គារ ១០កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ២៤៣ កប/អក/វក/លកអ. ចុះថ្ងៃ ចុះថ្ងៃអង្គារ ១០កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន ខ្មែរ អេឡិចទ្រីខល ផៅវ័រ គឺជាក្រុមហ៊ុនមានសកម្មភាពចម្បងផ្នែកផលិតថាមពលអគ្គិសនី និងទទួលបានវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មលេខ ០០០២៨៥៩៨ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០០៤។ ក្រុមហ៊ុននេះមានជួលកម្មករនិយោជិតសរុបចំនួន ៥៤នាក់ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខ្មែរ អេឡិចទ្រីខល ផៅវ័រ)*។
- យោងតាមលិខិតស្នើសុំ និងចាត់តាំងប្រតិភូចរចា មានឈ្មោះ និងស្នាមមេដៃកម្មករនិយោជិតដែលជាដើមបណ្តឹងសរុបចំនួន ៣២នាក់។

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតនៅតែទាមទារ ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួល ១៣០ភាគរយ ជូនកម្មករនិយោជិតដែលធ្វើការប្តូរវេនជាក់ស្តែង ចាប់ពីម៉ោង ២២យប់ ដល់ម៉ោង ៥ភ្លឺ ដែលមានចែងក្នុងមាត្រា ១៤៤ ថ្មី និងមាត្រា ១៣៩ នៃច្បាប់ស្តីពីការងារ**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារ ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលចំនួន ១៣០ភាគរយ ជូនកម្មករនិយោជិតដែលប្តូរវេនទៅធ្វើការវេនយប់ គិតចាប់ពីម៉ោង ២២យប់ ដល់ម៉ោង ៥ភ្លឺ។
- ភាគីទាំងពីរទទួលស្គាល់ថា ៖
    - កម្មករនិយោជិតនិយោជិតដែលជាដើមបណ្តឹងនៅក្នុងចំណុចវិវាទនេះ សរុបចំនួន ២០នាក់ ដោយពួកគាត់ចែកជាបួនក្រុម និងត្រូវធ្វើការផ្លាស់វេនគ្នា ជូនថ្ងៃ ជូនយប់ គឺចាប់ពីម៉ោង ៧ព្រឹក ដល់ម៉ោង ៣រសៀល, ពីម៉ោង ៣រសៀល ដល់ម៉ោង ១១យប់ និង ពីម៉ោង ១១យប់ ដល់ម៉ោង ៧ព្រឹក។
    - ចាប់ពីក្រុមហ៊ុនបើកដំណើរការ រហូតដល់បច្ចុប្បន្ន និយោជកផ្តល់ប្រាក់ឈ្នួលការងារវេនយប់ដូចគ្នា និងការងារវេនថ្ងៃ ពោលគឺមានចំនួន ១០០ភាគរយ ដូចគ្នា។ ក្រៅពីនេះ និយោជកផ្តល់អត្ថប្រយោជន៍ផ្សេងៗ ជូនកម្មករនិយោជិតប្រសើរជាច្បាប់កំណត់ ដូចជា កម្មករនិយោជិតធ្វើការបន្ថែមម៉ោង ឬការងារថ្ងៃឈប់សម្រាកបុណ្យទទួលបានប្រាក់ឈ្នួលចំនួន ២០០ភាគរយ និងទទួលបានការឈប់សម្រាកចំនួន ៨ថ្ងៃ ក្នុងមួយខែ។
    - នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ភាគីកម្មករនិយោជិតបានជួបចរចាជាមួយនិយោជកអំពីប្រាក់ឈ្នួលការងារវេនយប់ ចំនួន ១៣០ភាគរយ ប៉ុន្តែ ភាគីនិយោជកមិនយល់ព្រមនោះទេ ដោយលើកមូលហេតុថា និយោជកត្រូវការអំណះអំណាង ឬលិខិតបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចត្រឹមត្រូវច្បាស់លាស់ ទើបនិយោជកអាចសម្រេចបាន។
    - នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ ភាគីកម្មករនិយោជិតបានដាក់ពាក្យបណ្តឹងទៅក្រសួងការងារ ដោយមានការផ្សះផ្សា និងសម្រួលសម្រួលពីនាយកដ្ឋានវិវាទការងារ ក៏ប៉ុន្តែ ភាគីនិយោជកនៅតែប្រកាន់គោលជំហរដដែល។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា យោងតាមមាត្រា ១៤៤-ថ្មី នៃច្បាប់ស្តីពីការងារ និងសារាចរលេខ ១៨៤ កប/សរ ឆ្នាំ២០០៧ បានបញ្ជាក់ថា ការងារវេនយប់ចាប់ពីម៉ោង ១០យប់ ដល់ម៉ោង ៥ភ្លឺ ត្រូវទទួលបានប្រាក់ឈ្នួលចំនួន ១៣០ភាគរយ។ ហេតុនេះ និយោជកមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួលចំនួន ១៣០ភាគរយ ជូនកម្មករនិយោជិតធ្វើការវេនយប់។
- ភាគីនិយោជករក្សាគោលជំហរមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយហេតុថា ៖
    - ចាប់ពីពេលដំណើរក្រុមហ៊ុន រហូតមកដល់បច្ចុប្បន្ននិយោជកបានផ្តល់អត្ថប្រយោជន៍ផ្សេងៗ ជូនកម្មករនិយោជិតលើសច្បាប់កំណត់រួចហើយ។
    - នៅពេលចុះកិច្ចសន្យាការងារជាមួយនិយោជក ភាគីកម្មករនិយោជិតបានឯកភាពថា និងធ្វើការងារផ្លាស់ប្តូរវេន។

THE ARBITRATION COUNCIL

- ០ យោងតាមមាត្រា១៤៤-ថ្មី នៃច្បាប់ស្តីពីការងារ បានបញ្ជាក់ថា ការងារវេនយប់ គឺមានរយៈពេល ១១ម៉ោង បន្តបន្ទាប់គ្នា។ ក្នុងករណី ភាគីកម្មករនិយោជិតមិនបានធ្វើការរយៈពេល ១១ម៉ោង បន្តបន្ទាប់គ្នានោះទេ។
- ០ម្យ៉ាងទៀត នៅក្នុងសវនាការ ភាគីនិយោជកបានលើកឡើងថា ប្រសិនបើភាគីកម្មករនិយោជិតនៅតែទាមទារឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលការងារវេនយប់ចំនួន ១៣០ភាគរយនោះ និយោជកនឹងផ្លាស់ប្តូរអត្ថប្រយោជន៍ដែលធ្លាប់ផ្តល់ជូនកម្មករនិយោជិតឡើងវិញ ហើយភាគីនិយោជកក៏ឯកភាពដែរថា ចាប់តាំងពីដំណើរការក្រុមហ៊ុនមក មិនមានកិច្ចព្រមព្រៀង ឬកិច្ចសន្យាណាមួយបញ្ជាក់ពីការផ្លាស់ប្តូរអត្ថប្រយោជន៍ផ្សេងៗ ជាមួយប្រាក់ឈ្នួលការងារវេនយប់នោះទេ។

- ភាគីកម្មនិយោជិតបានឆ្លើយតបនឹងការលើកឡើងរបស់និយោជកខាងលើថា ក្នុងករណីដែលភាគីនិយោជកចង់ផ្លាស់ប្តូរអត្ថប្រយោជន៍ផ្សេងៗ ដែលធ្លាប់ផ្តល់ជូនកម្មករនិយោជិត ជាមួយនិងការផ្តល់ប្រាក់ឈ្នួលការងារវេនយប់ ចំនួន ១៣០ភាគរយនោះ គឺមិនត្រឹមត្រូវទេ ពីព្រោះយោងតាមមាត្រា ១៣ នៃច្បាប់ស្តីពីការងារ អត្ថប្រយោជន៍ផ្សេងៗ ដែលធ្លាប់ផ្តល់ជូនកម្មករនិយោជិតហើយ គឺត្រូវផ្តល់ជូនបន្តទៀត។ ម្យ៉ាងទៀត ចាប់តាំងពីចូលធ្វើការរហូតបច្ចុប្បន្នមិនមានកិច្ចព្រមព្រៀង ឬកិច្ចសន្យាណាមួយបញ្ជាក់ថា ការផ្តល់អត្ថប្រយោជន៍ផ្សេងៗ ត្រូវផ្លាស់ប្តូរ និងប្រាក់ឈ្នួលការងារវេនយប់ចំនួន ១៣០ភាគរយ នោះទេ។ ភាគីកម្មករនិយោជិតបានបញ្ជាក់បន្ថែមថា ប្រសិនបើភាគីនិយោជកចង់ផ្លាស់ប្តូរអត្ថប្រយោជន៍ផ្សេងៗមែន ក៏ផ្លាស់ប្តូរទៅចុះ ឱ្យតែភាគីនិយោជកអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់កំណត់។

## ហេតុផលនៃសេចក្តីសម្រេច ÷

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលចំនួន ១៣០ភាគរយ ជូនកម្មករនិយោជិតដែលប្តូរវេនទៅធ្វើការវេនយប់ ចាប់ពីម៉ោង ២២យប់ ដល់ម៉ោង ៥ភ្លឺ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួលចំនួន ១៣០ ភាគរយ ជូនកម្មករនិយោជិតដែលធ្វើការប្តូរវេន ចាប់ពីម៉ោង ២២យប់ ដល់ម៉ោង ៥ភ្លឺ ដែរ ឬទេ?

មាត្រា ១៤៤-ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣៩ និងមាត្រា ១៤៤ នៃច្បាប់ស្តីពីការងារ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលចូលជាធរមានថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ (តទៅនេះហៅថាមាត្រា ១៤៤-ថ្មី នៃច្បាប់ស្តីពីការងារ) ចែងថា៖ *"ពាក្យថា ពេលយប់ក្នុងច្បាប់នេះ មានន័យថា រយៈពេល ១១(ដប់មួយ)ម៉ោង បន្តបន្ទាប់គ្នាយ៉ាងតិច ដោយក្នុងនោះត្រូវមានពេលពីម៉ោង ២២ទៅម៉ោង ៥ភ្លឺ ផង។ ការងារពេលយប់ ត្រូវគិតពីម៉ោង ២២ទៅម៉ោង ៥ ភ្លឺ។*

*ក្រៅពីការងារបន្តបន្ទាប់ដែលក្រុមកម្មករផ្លាស់វេនគ្នាធ្វើការ ជូនថ្ងៃ ជូនយប់ ការងារវេនយាមត្រូវអាចមានធ្វើមួយផ្នែកនៃពេលយប់ជានិច្ច។ ការងារពេលយប់ត្រូវឱ្យប្រាក់ឈ្នួលតាមអាត្រា ១៣០% (មួយរយសាមសិបភាគរយ) នៃប្រាក់ឈ្នួលការងារពេលថ្ងៃ"។*

ចំណុចទី១ នៃសារាចរលេខ ១៨៥ កប/សរ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៧ ស្តីពី ប្រាក់ឈ្នួល នៃការងារពេលយប់ ចែងថា ៖ *"កម្មករនិយោជិតដែលធ្វើការនៅពេលយប់ ចន្លោះពីម៉ោង ២២ ដល់ម៉ោង ៥ភ្លឺ*

*ទោះបីធ្វើការផ្លាស់ប្តូរវេនគ្នាក្តី ឬធ្វើការជាអចិន្ត្រៃយ៍ក្តី កម្មករនិយោជិតទាំងនោះត្រូវបានប្រាក់ឈ្នួលស្មើនឹង ១៣០% (មួយរយសាមសិបភាគរយ) នៃប្រាក់ឈ្នួលការងារពេលថ្ងៃ។... "។*

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថាពាក្យថា "យប់" គឺរយៈពេល ១១ម៉ោង បន្តបន្ទាប់ ដែលត្រូវរាប់ពីពេលថ្ងៃលិច រហូតដល់ពេលមុនថ្ងៃរះ ដោយក្នុងរយៈពេលនោះ មានម៉ោង ១០យប់ ដល់ម៉ោង ៥ភ្លឺ ពោលគឺអាចរាប់ពីម៉ោង ៦ល្ងាច ដល់ ៥ភ្លឺ ឬពីម៉ោង ៧ល្ងាច ដល់ម៉ោង ៦ព្រឹក ជាដើម។ ពាក្យ យប់ គឺមានរយៈពេល ១១ម៉ោង បន្តបន្ទាប់គ្នា ប៉ុន្តែរយៈពេល ១១ម៉ោង បន្តបន្ទាប់នេះ មិនមែនកំណត់ថា ជាការងារពេលយប់ទាំងអស់នោះទេ។ ការងារពេលយប់ គឺសំដៅដល់តែការងារធ្វើចាប់ពីម៉ោង ១០ យប់ដល់ម៉ោង ៥ភ្លឺ ប៉ុណ្ណោះ។ *(សូមមើលបង្គាប់អាជ្ញាកណ្តាល លេខ ១១៦/០៩-ស៊ីនតាយ ហេតុផលចំណុចវិវាទទី៧, លេខ ០៦២/១០- ចុងយ៉ូវ ហេតុផលនៃចំណុចវិវាទទី៤, លេខ ៦៨/១០- យូ អេស អេ ហេតុផលចំណុចវិវាទទី៩ , និង លេខ ០៦៣/១៩ - អាកាសយានដ្ឋានអន្តរជាតិសៀមរាប ហេតុផលនៃចំណុចវិវាទទី៥)*

លើសពីនេះទៀត យោងតាមមាត្រា ១៤៤-ថ្មី នៃច្បាប់ស្តីពីការងារ និងចំណុចទី១ នៃសារាចរលេខ ១៨៥ កប/សរ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការងារវេនយប់ គឺគិតពីម៉ោង ២២ ទៅម៉ោង ៥ ភ្លឺ។ ហេតុនេះ ចំពោះកម្មករនិយោជិតដែលធ្វើការក្នុងពេលម៉ោងនេះ មានសិទ្ធិទទួលបានប្រាក់ឈ្នួលលើសកម្មករនិយោជិតវេនថ្ងៃចំនួន ៣០ ភាគរយ (អត្រា ១៣០ ភាគរយ នៃប្រាក់ឈ្នួលការងារពេលថ្ងៃ)។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១១៩/០៧-រូយ៉ាល់ក្រោនចិក ហេតុផលនៃចំណុច វិវាទទី១៦, លេខ ១១៩/០៩-អេស អិល ហេតុផលនៃចំណុចវិវាទទី១, លេខ២៥០/១៥-អិល អិល អេស ព្រីនធីង ចំណុចវិវាទទី១៣, លេខ ០០១/១៧-ដាយអ៊ីម៉ិន ស៊ីធី ប្រាយវេត លីមីធីត ខមភេនី ហេតុផលនៃចំណុចវិវាទទី២, លេខ ០០២/១៧-ប៉ោយប៉ែត បែហ្សត ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី១, លេខ ០១០/១៨ - ហ្វូម៉ី (ខេមបូឌា) អ៊ីមផត អិចផត ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី៣, និង លេខ ០៨១/១៩ - ខ្មែរ អេឡិកទ្រីខល ផៅវ័រ ហេតុផលនៃចំណុចវិវាទទី២)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញា-កណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

យោងតាមមាត្រា១៤៤-ថ្មី នៃច្បាប់ស្តីពីការងារ និងសារាចរលេខ ១៨៥ ខាងលើ ក្រុមប្រឹក្សាអាជ្ញា-កណ្តាលយល់ឃើញថា កម្មករនិយោជិតដែលធ្វើការងារវេនយប់ចាប់ពីម៉ោង ១០ យប់ ដល់ម៉ោង ៥ ភ្លឺ គឺត្រូវទទួលបានប្រាក់ឈ្នួលចំនួន ១៣០ ភាគរយ នៃប្រាក់ឈ្នួលការងារវេនថ្ងៃ ទោះបីជាកម្មករនិយោជិតធ្វើការផ្លាស់ប្តូរវេនគ្នា ជួនថ្ងៃ ជួនយប់ យ៉ាងណាក៏ដោយឱ្យតែម៉ោងការងាររបស់ពួកគាត់ស្ថិតក្នុងម៉ោង ១០ ដល់ម៉ោង ៥ភ្លឺ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការអនុវត្តរបស់និយោជកដែលបានផ្លាស់ប្តូរវេនការងាររបស់កម្មករនិយោជិតជួនថ្ងៃ ជួនយប់ ចំពោះកម្មករនិយោជិតដែលប្តូរមកធ្វើការនៅវេនយប់ចាប់ពីម៉ោង ១០យប់ ដល់ម៉ោង ៥ភ្លឺ និយោជកផ្តល់ប្រាក់ឈ្នួលចំនួន ១០០ភាគរយ ដូចគ្នានឹងប្រាក់ឈ្នួលការងារវេនថ្ងៃដែរនោះ គឺជាការអនុវត្តដែលមិនត្រឹមត្រូវតាមច្បាប់នោះទេ ពីព្រោះបទប្បញ្ញត្តិច្បាប់ខាងលើ បានបញ្ជាក់យ៉ាងច្បាស់ថា កម្មករនិយោជិតធ្វើការវេនយប់ត្រូវទទួលបានប្រាក់ឈ្នួលចំនួន ១៣០ ភាគរយ នៃប្រាក់ឈ្នួលការងារវេនថ្ងៃ។ ហេតុនេះ និយោជកមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួលចំនួន ១៣០ភាគរយ នៃប្រាក់ឈ្នួលការងារពេលថ្ងៃ ជូនកម្មករនិយោជិត ដែលផ្លាស់ប្តូរវេនទៅធ្វើការពេលយប់គិតចាប់ពីម៉ោង ១០យប់ ដល់ម៉ោង ៥ភ្លឺ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេច បង្គាប់ឱ្យនិយោជកផ្ដល់ប្រាក់ឈ្នួលចំនួន ១៣០ភាគរយ នៃប្រាក់ឈ្នួលការងារពេលថ្ងៃ ជូនកម្មករនិយោជិតដែលប្ដូរវេនមកធ្វើការវេនយប់ ចាប់ពីម៉ោង ២២យប់ ដល់ម៉ោង ៥ភ្លឺ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចដូចតទៅ ៖

## សម្រេច

**ចំណុចវិវាទ ៖**

- បង្គាប់ឱ្យនិយោជកផ្ដល់ប្រាក់ឈ្នួលចំនួន ១៣០ភាគរយ នៃប្រាក់ឈ្នួលការងារពេលថ្ងៃ ជូនកម្មករនិយោជិតដែលប្ដូរវេនមកធ្វើការវេនយប់ ចាប់ពីម៉ោង ២២យប់ ដល់ម៉ោង ៥ភ្លឺ។

**ប្រភេទនៃសេចក្ដីបង្គាប់ ៖ សេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច**

សេចក្ដីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីបង្គាប់ ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **សេង ឡុចហ៊ុន**

ហត្ថលេខា ៖ ------------------------------

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖------------------------------

**ប្រធានក្រុមអាជ្ញាកណ្ដាល ៖**

ឈ្មោះ ៖ **ម៉ែន ម៉ុនណា**

ហត្ថលេខា ៖ ------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**ក្រុមប្រឹក្សាអាជ្ញាកណ្តាល**
**ជម្រាបជូន**
**- លោកនាយកក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ័រ**
**- លោក-លោកស្រីតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយ វិវាទការងាររួម នៅក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ័រ**

**កម្មវត្ថុ ៖** ការកែតម្រូវសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ០៤០/២០-ខ្មែរ អេឡិកទ្រីខល ផៅវ័រ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០

**យោង ៖** សេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ០៤០/២០-ខ្មែរ អេឡិកទ្រីខល ផៅវ័រ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាល សូមធ្វើការកែតម្រូវពាក្យពេចន៍នៃសេចក្តីបង្គាប់អាជ្ញាកណ្តាល សំណុំរឿងលេខ ០៤០/២០-ខ្មែរ អេឡិកទ្រីខល ផៅវ័រ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ ដែលមាននៅក្នុង**ទំព័រទី២** ដូចខាងក្រោម ៖

- **ពាក្យពេចន៍ដើម ៖**

"**បញ្ហានីតិវិធី៖**

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖"

- **ពាក្យពេចន៍ដែលត្រូវយកមកជំនួស ៖**

"**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិត នៃក្រុមហ៊ុន ខ្មែរ អេឡិចទ្រីខល ផៅវ័រ ស្តីពីការទាមទារសុំឱ្យក្រុមហ៊ុនកែលម្អលក្ខខណ្ឌការងារចំនួន ១ចំណុច ឱ្យបានល្អប្រសើរ។ បន្ទាប់ពីទទួលបានពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញ ឱ្យធ្វើការដោះស្រាយវិវាទការងារនេះទៅតាមនីតិវិធីច្បាប់ និងធ្វើការផ្សះផ្សានៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០ ប៉ុន្តែ មិនទទួលបានលទ្ធផលសះជានឹងគ្នានោះទេ។ ចំណុចវិវាទដែលមិនសះជាចំនួន ១ចំណុច ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ខ្មែរ អេឡិចទ្រីខល ផៅវ័រ លេខ ៦២៩ ក.ប/អក/វក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងផ្សះផ្សាលើករណីមិនសះជាចំនួន ១ចំណុចនេះ នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ៨ និង ៣០ នាទីព្រឹក។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមស្វះរកនូវអង្គហេតុផ្សេងៗដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជា ចំនួន ១ចំណុចនេះ និងបានផ្សះផ្សាលើចំណុចវិវាទបន្ថែមទៀត ប៉ុន្តែ មិនទទួលបានលទ្ធផលសះជានឹងគ្នានោះទេ។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារភស្តុតាង និងថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារភស្តុតាង។

ភាគីទាំងពីរបានឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ ទៅយ៉ាងយូរ ត្រឹមថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖"

**បញ្ជាក់ ៖** ការកែប្រែនេះ មិនប៉ះពាល់ដល់អង្គសេចក្តី និងសេចក្តីសម្រេចផ្សេងទៀត របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលចេញនៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ ទេ។

សេចក្តីកែតម្រូវនេះ នឹងរក្សាទុកនៅក្នុងសំណុំរឿង លេខ ០៤០/២០-ខ្មែរ អេឡិកទ្រីខល ផៅវ័រ នៅឯលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល និងចម្លងជូនភាគីកម្មករនិយោជិត ចំនួន ០១ច្បាប់ និងភាគីនិយោជក ចំនួន ០១ច្បាប់។

សូមលោក-លោកស្រីជ្រាប និងទទួលនូវការរាប់អានអំពីយើងខ្ញុំ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០២០

**ហត្ថលេខា**

**ក្រុមអាជ្ញាកណ្តាល**

THE ARBITRATION COUNCIL

**ម៉ែន ម៉ុនឈា** **សេង ខួចហ៊ីន** **អន ណាន**